រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# សកម្មភាពឃុំ សង្កាត់ នៅក្នុងវិស័យអប់រំ

ខែកក្កដា ឆ្នាំ២០០៦

## មាតិកា


| | | |
|---|---|---|
| អារម្ភកថា | | ១ |
| ១. | ប្រព័ន្ធអប់រំនៅកម្ពុជា និងការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ | ៣ |
| ២. | ការគាំពារ និងការអភិវឌ្ឍកុមារតូច | ៩ |
| ៣. | ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ | ១៤ |
| ៤. | ការអប់រំអក្ខរកម្ម | ១៨ |
| ៥. | បំណិនជីវិត | ២០ |
| ៦. | សមភាពយេនឌ័រក្នុងការអប់រំ | ២៣ |
| ៧. | គុណភាពនៃការអប់រំ | ២៦ |

# អារម្ភកថា

សៀវភៅនេះរៀបរៀងឡើង ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ដោយមានកិច្ចសហការ និងគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងស្ថាប័នផ្តល់ជំនួយ : យូនីសេហ្វ គម្រោងភាពជាដៃគូ ដើម្បីអភិបាលកិច្ចមូលដ្ឋាន និងគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់។

សៀវភៅនេះ នឹងផ្តល់ព័ត៌មានសំខាន់ៗជាសង្ខេបអំពីប្រព័ន្ធអប់រំនៅកម្ពុជា សារៈសំខាន់នៃការគាំពារ និងការអភិវឌ្ឍកុមារតូច និងបញ្ហាសមភាពយេនឌ័រក្នុងវិស័យអប់រំ។ ព័ត៌មានទាំងនេះ នឹងជួយពង្រីកចំណេះដឹងដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានយល់កាន់តែច្បាស់ពីសារៈសំខាន់នៃការអប់រំ និងជំរុញការអនុវត្តតួនាទីរបស់ខ្លួន ដើម្បីកែលម្អសេវាអប់រំឱ្យបានសម្រេចតាមគោលដៅទាំង៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា។

សៀវភៅនេះ នឹងប្រើប្រាស់ជាឯកសារបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ស្តីពី**សកម្មភាពឃុំ សង្កាត់ក្នុងវិស័យអប់រំ** និងប្រើប្រាស់ជាឯកសារផ្សព្វផ្សាយចំណេះដឹងទូទៅដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាប និងចូលរួមចំណែកជំរុញការអភិវឌ្ឍវិស័យអប់រំឱ្យកាន់តែមានភាពល្អប្រសើរឡើង។





គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការរួមចំណែករៀបរៀងសៀវភៅនេះ។ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់សង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះ នឹងផ្តល់សារៈសំខាន់យ៉ាងច្រើនសម្រាប់អ្នកប្រើប្រាស់គ្រប់រូប។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ នឹងទទួលស្វាគមន៍ជានិច្ច នូវមតិទិតៀនស្ថាបនាដើម្បីកែលម្អសៀវភៅនេះ។

# ១. ប្រព័ន្ធអប់រំនៅកម្ពុជា និងការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

## ១.១. និយមន័យ

**ការអប់រំ** គឺជាដំណើរការនៃការរៀនសូត្រ ឬការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍន៍ ផ្នែកកាយប្រាជ្ញា ស្មារតី និងសីលធម៌របស់បុគ្គល តាមរយៈកម្មវិធីច្បាស់លាស់ ឬតាមមធ្យោបាយផ្សេងៗទៀត ដែលអ្នករៀនសូត្រទាំងនោះអាចទទួលបានចំណេះដឹង ជំនាញ សមត្ថភាព និងបំណិនជីវិតសម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់សង្គមជាតិទាំងមូល។

**ភាពក្រីក្រ** គឺជាភាពនៃការខ្វះអាហារ ខ្វះសម្លៀកបំពាក់ ខ្វះទីជម្រករស់នៅ ឬគ្មានទីជម្រកសម្រាប់រស់នៅ ខ្វះសេវាសុខភាព សេវាអប់រំ និងប្រព័ន្ធគមនាគមន៍។

## ១.២. ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការអប់រំនៅប្រទេសកម្ពុជា

ក). ច្បាប់រដ្ឋធម្មនុញ្ញ

- **មាត្រា៤៧** : មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។
- **មាត្រា៦៥** : រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។
- **មាត្រា៦៨** : រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតមានបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវទទួលបានការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។ រដ្ឋជួយផ្សព្វផ្សាយ និងលើកតម្កើងសាលាបាលី និងពុទ្ធិកសិក្សា។





ខ). **ប្រកាសលេខ ៥១៣ អយក.ប្រក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការលុបបំបាត់ការប្រមូល និងរៃអង្គាសប្រាក់ពីសិស្ស នៅតាមសាលារៀនបឋមសិក្សា និងមធ្យមសិក្សាសាធារណៈ**

**ប្រការ១** : គ្រប់សាលារៀនចំណេះទូទៅសាធារណៈ (បឋមសិក្សា និងមធ្យមសិក្សា) ហាមដាច់ខាតមិនឱ្យមានការប្រមូល ឬរៃអង្គាសប្រាក់ ឬការសុំសម្ភារផ្សេងៗក្រៅផ្លូវការលើគ្រប់រូបភាពពីសិស្ស។

## ១.៣. គោលដៅទាំង៦នៃការអប់រំសម្រាប់ទាំងអស់គ្នា

១. កែលម្អការអប់រំ និងថែទាំកុមារតូចឱ្យបានទូលំទូលាយ និងការអប់រំពិសេស សម្រាប់កុមារដែលងាយរងគ្រោះ និងក្រខ្សត់។

២. ធានាថានៅឆ្នាំ២០១៥កុមារទាំងអស់ ពិសេសកុមារដែលស្ថិតក្នុងស្ថានភាពលំបាក និងកុមារជនជាតិដើមភាគតិចបានទទួល និងបំពេញចប់នូវកាតព្វកិច្ចអប់រំបឋមសិក្សា ដោយឥតបង់ថ្លៃ និងប្រកបដោយគុណភាព។

៣. ធានាថា តម្រូវការរៀនសូត្ររបស់យុវវ័យ និងជនពេញវ័យគ្រប់រូបត្រូវបានដោះស្រាយ តាមរយៈការផ្ដល់ឱកាសស្មើភាពក្នុងការចូលរួមក្នុងកម្មវិធីសិក្សាសមស្រប និងបណ្ដុះបណ្ដាលជំនាញជីវិត (បំណិនជីវិត)។

៤. ធានាសម្រេចឱ្យបានការរីកចម្រើនចំនួន៥០ភាគរយ នៅក្នុងកម្រិតអក្ខរកម្មជនពេញវ័យ នៅមុនបំណាច់ឆ្នាំ២០១៥ ពិសេសសម្រាប់ស្ត្រី និងឱកាសស្មើភាពគ្នាក្នុងការអប់រំមូលដ្ឋាន និងការអប់រំបន្តសម្រាប់ជនពេញវ័យទាំងអស់។

៥. លុបបំបាត់គម្លាតយេនឌ័រនៅសាលាបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០០៥ និងធ្វើឱ្យបានសម្រេចនូវសមភាពយេនឌ័រក្នុងវិស័យអប់រំនៅឆ្នាំ២០១៥ ដោយផ្ដោតការយកចិត្តទុកដាក់លើការធានាឱ្យកុមារី បានទទួលនូវលទ្ធភាពចូលរៀនពេញលេញ និងស្មើភាពហើយសម្រេចបាននូវការអប់រំមូលដ្ឋានប្រកបដោយគុណភាព។





៦. កែលម្អលើគ្រប់ទិដ្ឋភាពនៃគុណភាពអប់រំ និងធានាបាននូវគុណភាពល្អប្រសើរបំផុត ដើម្បីឱ្យមនុស្សគ្រប់រូបដណ្ដើមបានលទ្ធផលរៀនសូត្រក្នុងកម្រិតមួយដែលអាចទទួលយកបាន និងមានការទទួលស្គាល់ ជាពិសេសផ្នែកអក្សរសាស្ត្រ លេខនព្វន្ត និងជំនាញសម្រាប់ចិញ្ចឹមជីវិត។

## ១.៤. គោលការណ៍៤យ៉ាងនៃការអប់រំ

- ដើម្បីទទួលចំណេះដឹង (ការចេះអាន ចេះសរសេរ)។
- ដើម្បីមានបំណិន និងជំនាញសម្រាប់ជីវិត។
- ដើម្បីក្លាយជាមនុស្សល្អ ប្រកបដោយសីលធម៌រស់នៅល្អ។
- ដើម្បីរស់នៅជាមួយគ្នាក្នុងសង្គមប្រកបដោយសុខសន្តិភាព និងសុខដុមរមនា។

## ១.៥. ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

បច្ចុប្បន្នប្រព័ន្ធអប់រំប្រទេសកម្ពុជា គឺជាបរិយាប័ន្ន (ការអប់រំបញ្ចូលគ្នា) មានន័យថា ទាំងកុមារា និងកុមារីមានសិទ្ធិទទួលបានការអប់រំស្មើៗគ្នា ទោះបីក្រីក្រ ពិការ កំព្រា កុមារជនជាតិដើមភាគតិច កុមារនៅតំបន់ដាច់ស្រយាល កុមារអនាថា ...។ល។ សេវាអប់រំសាធារណៈនៅកម្ពុជា មិនតម្រូវឱ្យបង់ប្រាក់ឡើយ។

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

| កម្រិតអប់រំ | កម្រិតថ្នាក់ | អាយុសមស្រប |
|---|---|---|
| មត្តេយ្យសិក្សា | ៣ កម្រិតថ្នាក់ | ៣-៥ ឆ្នាំ |
| បឋមសិក្សា | ៦ កម្រិតថ្នាក់ | ៦-១១ ឆ្នាំ |
| មធ្យមសិក្សាបឋមភូមិ | ៣ កម្រិតថ្នាក់ | ១២-១៤ |
| មធ្យមសិក្សាទុតិយភូមិ | ៣ កម្រិតថ្នាក់ | ១៥-១៧ |
| ឧត្តមសិក្សា | សិក្សាពី ៤-៧ ឆ្នាំ | ១៨ ឡើងទៅ |

## ១.៦. កន្លែងផ្តល់ការអប់រំ

- **នៅសាលារៀន** : ថ្នាក់ថែទាំកុមារ មត្តេយ្យសាលា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ . . .។ ល ។
- **នៅផ្ទះ (គ្រួសារ)** : ទទួលការអប់រំពីឪពុកម្តាយ ជីដូនជីតា ពីសាច់ញាតិ និងបងប្អូន . . .។ល ។
- **សហគមន៍ (វត្តអារាម សាលាឃុំ)** : ថ្នាក់អក្ខរកម្មថ្នាក់ហ្វឹកហ្វឺនពីបំណិនជីវិត និងការងារអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ . . . ។ល ។



១. ប្រព័ន្ធអប់រំនៅកម្ពុជា និងការអប់រំជាយុត្តិសាស្ត្រកាត់បន្ថយភាពក្រីក្រ

## ១.៧. ការអប់រំចូលរួមកាត់បន្ថយភាពក្រីក្រ

*ភាពក្រីក្រ* គឺជាភាពនៃការខ្វះអាហារ ខ្វះសម្លៀកបំពាក់ ខ្វះទីជម្រករស់នៅ ឬគ្មានទីជម្រកសម្រាប់រស់នៅ ខ្វះសេវាអប់រំ សេវាសុខភាព និងប្រព័ន្ធគមនាគមន៍។

ការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ព្រោះការអប់រំ នឹងធ្វើឱ្យប្រជាពលរដ្ឋ ÷

- មានចំណេះដឹងដើម្បីបង្កើនផលិតភាពកសិកម្ម។
- មានចំណេះដឹងក្នុងការការពារ និងថែរក្សាសុខភាព។
- មានជំនាញក្នុងការប្រកបការងារដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសារ។
- មានសមត្ថភាពក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។
- មានបំណិនក្នុងការរស់នៅក្នុងសហគមន៍ប្រកបដោយភាពសុខសាន្ត។
- . . . ។ល។

# ២. ការគាំពារ និងការអភិវឌ្ឍកុមារតូច

## ២.១. ការអភិវឌ្ឍកុមារតូច

ការគាំពារ និងការអភិវឌ្ឍកុមារតូចនៅវ័យដំបូង ពិតជាមានសារប្រយោជន៍ខ្លាំងណាស់ ព្រោះវានឹងមានផលប៉ះពាល់ជាវិជ្ជមានលើកុមារ ជាពិសេសលើការអភិវឌ្ឍផ្នែកខួរក្បាល ដែលជាទូទៅការអភិវឌ្ឍផ្នែកខួរក្បាលនេះ វាលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងខែ និងឆ្នាំដំបូងរបស់កុមារ។ កង្វះការយកចិត្តទុកដាក់ក្នុងការគាំពារកុមារតូច គឺនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានឥតឈប់ឈរទៅលើកុមារ ដែលនាំឱ្យមានការខូចខាតលើសពីអ្វីដែលយើងបានគិតទុក។

ជាការសំខាន់ណាស់ដែលឪពុកម្តាយត្រូវយកចិត្តទុកដាក់ លើកទឹកចិត្ត និងត្រូវនិយាយលេងជាមួយកូនតាមដែលអាចធ្វើទៅបាន។

## ២.២. គំនិតសំខាន់ៗ ដែលអាចជួយជំរុញដល់ការអភិវឌ្ឍរបស់កុមារតូច

- ការពារកុមារពីគ្រោះថ្នាក់ដល់រាងកាយ
- ផ្តល់អាហារូបត្ថម្ភ និងការថែទាំសុខភាពឱ្យបានគ្រប់គ្រាន់
- ផ្តល់ថ្នាំបង្ការឱ្យបានគ្រប់គ្រាន់
- ផ្តល់ភាពជិតស្និទ្ធជាមួយមនុស្សចាស់





- មានមនុស្សចាស់ដែលអាចយល់ និងឆ្លើយតបទៅកុមារ
- មានវត្ថុឱ្យកុមារមើល ប៉ះ ស្តាប់ ឮ ស្រង់ក្លិន និងភ្លក្សរសជាតិ (ភ្លក្សរសជាតិសម្រាប់កុមារអាយុលើសពី៦ខែ)
- ផ្តល់ឱកាសឱ្យកុមាររកនឹក និងស្រាវជ្រាវរកពាក្យដែលគេចង់ប្រើ
- យកចិត្តទុកដាក់ចំពោះការប្រើប្រាស់ភាសា (ពាក្យនិយាយស្តី) ជាមួយកុមារ
- យកចិត្តទុកដាក់ និងគាំទ្រក្នុងការទទួលនូវសមត្ថភាពថ្មី ការអភិវឌ្ឍជំនាញ ភាសា និងការគិត
- សង្កេតលើឥរិយាបថរបស់កុមារ
- ផ្តល់ឱកាសឱ្យកុមារបានលេង។

## ២.៣. ការអប់រំកុមារតូច

មធ្យោបាយសំខាន់ដែលជួយកុមារឱ្យមានការអភិវឌ្ឍល្អ គឺការបញ្ជូនកូនទៅថ្នាក់មត្តេយ្យ នៅពេលគេមានអាយុចាប់ពី៣ទៅ៥ឆ្នាំ។

ការបញ្ជូនកុមារឱ្យទៅរៀននៅថ្នាក់មត្តេយ្យ មានសារប្រយោជន៍ជាច្រើន÷

- ជំរុញឱ្យមានការអភិវឌ្ឍខាងរូបរាងកាយ ប្រាជ្ញា ស្មារតី អារម្មណ៍ និងសង្គមរបស់កុមារ។
- លើកទឹកចិត្តកុមារឱ្យមានការត្រៀមទុកជាមុន សម្រាប់ការចូលរៀនសាលាបឋមសិក្សា។

- កុមារបានចូលថ្នាក់មត្តេយ្យ និងមានសកម្មភាពសិក្សានៅសាលាបឋមសិក្សាបានល្អជាងកុមារ ដែលមិនបានឆ្លងថ្នាក់មត្តេយ្យ។
- ជួយកែលម្អការចុះឈ្មោះចូលរៀនថ្នាក់ទី១ នៅពេលកុមារគ្រប់អាយុ៦ឆ្នាំ។
- ជួយកាត់បន្ថយអត្រារៀនត្រួតថ្នាក់ និងបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា។
- ផ្តល់ឱកាសឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិអប់រំ និងការអភិវឌ្ឍ។

## ២.៤. សេវាកម្មអប់រំមួយចំនួនសម្រាប់ការអប់រំកុមារតូច (អាយុពី៣~៥ឆ្នាំ)

| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| **សេវាមត្តេយ្យសាធារណៈ** (មិនតម្រូវឱ្យយកប្រាក់)<br>– កម្មវិធីសិក្សាមត្តេយ្យសាធារណៈ<br>– មុខវិជ្ជាសិក្សាសំខាន់ៗរួមមាន : បុរេគណិត បុរេសំណេរ សិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្ត។<br>– កាលវិភាគ : ៤ម៉ោងក្នុង១ថ្ងៃ ៥ថ្ងៃក្នុង១សប្តាហ៍ ១៩០ថ្ងៃក្នុង១ឆ្នាំ<br>– ផលធៀបសិស្សថ្នាក់ : សិស្ស៣៥នាក់ក្នុង១ថ្នាក់ | ក្រសួងអប់រំ យុវជន និងកីឡា | តុលា-កក្កដា (៩ខែ) |





| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| – បញ្ជូនគ្រូដែលមានការបណ្តុះបណ្តាលទៅបង្រៀន | | ២ឆ្នាំ |
| – បណ្តុះបណ្តាលគ្រូមត្តេយ្យបំប៉នសមត្ថភាពគ្រូ | | |
| – ផ្តល់សម្ភារគ្រូ និងសម្ភារបង្រៀន | | |
| – ថវិកាសកម្មភាពជាអាទិភាព សម្រាប់សកម្មភាពត្រួតពិនិត្យ | មន្ទីរអប់រំខេត្តក្រុង | ប្រចាំឆ្នាំ |
| – ថវិកាសកម្មភាពជាអាទិភាពសម្រាប់ផលិតសម្ភារបង្រៀន សម្រាប់សកម្មភាពសិក្សានៅផ្ទះ | មន្ទីរអប់រំខេត្តក្រុង | |
| **មត្តេយ្យសហគមន៍** (មិនតម្រូវឱ្យបង់ប្រាក់)<br>– មានមុខវិជ្ជាសិក្សាសំខាន់ៗរួមមាន : បុរេគណិត បុរេសំណេរ សិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្ត។<br>– កាលវិភាគ : ២ម៉ោងក្នុង១ថ្ងៃ ៥ថ្ងៃក្នុង១សប្តាហ៍ ១៩០ថ្ងៃក្នុង១ឆ្នាំ<br>– ផលធៀបសិស្សថ្នាក់ : សិស្ស២៥នាក់ក្នុង១ថ្នាក់ | ឃុំ សង្កាត់ | តុលា-កក្កដា (៩ខែ) |
| – បញ្ជូនគ្រូដែលបានការបណ្តុះបណ្តាលទៅបង្រៀន | ឃុំ សង្កាត់ | ១៦ថ្ងៃ |

| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| – បណ្តុះបណ្តាលគ្រូមត្តេយ្យបំប៉នសមត្ថភាពគ្រូ<br>– ផ្ទាក់រៀន និងថវិកាឧបត្ថម្ភគ្រូ សម្ភារគ្រូ សម្ភារបង្រៀន | ក្រសួង ឬមន្ទីរអប់រំ<br>ឃុំ ឬសហគមន៏ | |
| **មត្តេយ្យគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល** ( ប្រហាក់ប្រហែលមត្តេយ្យសហគមន៏) | | |
| **មត្តេយ្យឯកជន** ( សេវាបង់ប្រាក់) | ឯកជន | |
| **កម្មវិធីសិក្សាតាមខ្នងផ្ទះ និងសកម្មភាពអប់រំឪពុក ម្តាយ** ( ជាសេវាដែលផ្តល់តាមរយៈក្រុមម្តាយដល់កុមារ) | ក្រសួង ឬមន្ទីរអប់រំ និងឪពុកម្តាយ | ប្រជុំប្រចាំខែ ( មិនកំណត់) |





# ៣. ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ

## ៣.១. និយមន័យ

ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ សំដៅដល់ការអប់រំប្រាំបួនថ្នាក់ដំបូង គឺចាប់ពីថ្នាក់ទីមួយ ដល់ថ្នាក់ទីប្រាំបួននៃការអប់រំចំណេះទូទៅក្នុងប្រព័ន្ធ ឬការអប់រំកម្រិតសមមូល ។ ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធមានគោលបំណង ដើម្បីបំពេញសេចក្តីត្រូវការចំណេះដឹងជាមូលដ្ឋាន សម្រាប់ប្រជាពលរដ្ឋ និងជាមូលដ្ឋានសម្រាប់ការសិក្សាបន្តទៀត ។

## ៣.២. សេវាកម្មអប់រំសម្រាប់កម្រិតបឋមសិក្សា (កុមារអាយុពី៦_១១ឆ្នាំ)

| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| – ផ្តល់ជូន៦កម្រិតថ្នាក់ ( ថ្នាក់ទី១ដល់ទី៦)<br>– ជាសេវាកម្មសាធារណៈដោយមិនមានការបង់ប្រាក់<br>– ជាសេវាអប់រំសម្រាប់ទាំងអស់គ្នា ការអប់រំបញ្ចូលគ្នា<br>– ផលធៀបសិស្សថ្នាក់ : សិស្ស៤៥នាក់ ក្នុង ១ថ្នាក់<br>– កាលវិភាគសិក្សា : ៦ម៉ោងក្នុងមួយថ្ងៃ ៥ថ្ងៃក្នុង១សប្តាហ៏ ៣៨សប្តាហ៏ក្នុង១ឆ្នាំ ( ប្រហែល១៩0ថ្ងៃ) | – ក្រសួងឬមន្ទីរអប់រំ | |

| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| – កាលវិភាគអាចកែសម្រួលតាមស្ថានភាពតំបន់ (សារាចរណែនាំលេខ៣៤៣៥) ។ | – សាលារៀបចំ និង មន្ទីរអប់រំអនុម័ត | |
| – បញ្ជូនគ្រូមានសមត្ថភាពទៅបង្រៀន | – មន្ទីរអប់រំ | – រយៈពេល ២ឆ្នាំ |
| – មានការបណ្តុះបណ្តាលគ្រូ និងបំប៉នសមត្ថភាពគ្រូ ការប្រជុំបច្ចេកទេស | – ក្រសួងឬមន្ទីរអប់រំ | – ជាក់ស្តែង |
| – មានភាពអនុគ្រោះទុក្ខលំបាករបស់គ្រូក្នុងទីដាច់ស្រយាល ឬទីជនបទ | – សាលារៀបចំ និង មន្ទីរអប់រំអនុម័ត | – ជាក់ស្តែង |
| – បង្រៀនពីរវេន បើមានសិស្សលើសពី ៥៥នាក់ក្នុងថ្នាក់ | | – ជាក់ស្តែង |
| – ការបង្រៀនថ្នាក់គួបនៅពេល មិនមានគ្រូគ្រប់គ្រាន់ | | – ជាក់ស្តែង |
| – បន្ថែមប្រាក់ឧបត្ថម្ភចំពោះ គ្រូដែលបង្រៀនថ្នាក់គួប ឬពីរវេន | | – ចាប់ផ្តើមនៅពាក់កណ្តាលខែកញ្ញា |
| – ការចុះឈ្មោះ និងចុះបញ្ជីកុមារដែលមានអាយុត្រូវចូលរៀន និងរៀបចំយុទ្ធនាការចុះឈ្មោះចូលរៀន | – ក្រសួងឬមន្ទីរអប់រំ និងសាលារៀន | |
| – ការចុះឈ្មោះសិស្សដែលផ្ទេរសាលា ដោយមានឯកសារយោងមកជាមួយ | – ឃុំ សង្កាត់ | |
| – រក្សាកុមារឱ្យរៀនបន្ត និងផ្តល់ប្រព័ន្ធអប់រំក្នុងសាលា | – សាលារៀន | – ប្រចាំឆ្នាំសិក្សា |
| – សិស្សដែលបានបោះបង់ចោលការសិក្សា | – សាលារៀន | |





| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| អាចចុះឈ្មោះចូលរៀនម្តងទៀត | | |
| – ផ្តល់សៀវភៅមេរៀន៤មុខវិជ្ជាឱ្យសិស្សសម្រាប់សិក្សា ជារៀងរាល់ឆ្នាំ ដោយឥតបង់ថ្លៃ | – សាលារៀន | |
| – ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សម្រាប់ការអភិវឌ្ឍសាលារៀនទាំងមូល | – សាលារៀន និង គណៈកម្មការទ្រទ្រង់សាលា | – ទៀងទាត់ជាប្រចាំ |
| – សាលានីមួយៗទទួលបានថវិកា៦00.000 រៀល និង៧000រៀលក្នុងសិស្សម្នាក់ក្នុង១ឆ្នាំ ពីថវិកាសកម្មភាពជាអាទិភាពសម្រាប់ការអភិវឌ្ឍសាលារៀន : ជួសជុលសម្ភារសាលាធុនតូច ផ្គត់ផ្គង់សម្ភារការិយាល័យ សម្ភារកីឡា ឧបករណ៍កសិកម្ម បរិស្ថាន ការហ្វឹកហ្វឺន គ្រូបង្រៀនការិយាល័យអប់រំស្រុក (គណៈកម្មាធិការគ្រប់គ្រងថវិកា) ត្រួតពិនិត្យមើលពីការប្រើប្រាស់ថវិកាសម្រាប់សកម្មភាពអាទិភាពរបស់សាលា | – ក្រសួងអប់រំ | – ជាក់ស្តែង |
| – ផ្តល់គ្រូជាប់កិច្ចសន្យា គ្រូស្ម័គ្រចិត្ត (នៅខេត្តមួយចំនួន) | – ការិយាល័យអប់រំស្រុក ខណ្ឌ | |
| – ការត្រួតពិនិត្យសាលា | – ក្រសួងអប់រំ | |

## ៣.៣. សេវាកម្មអប់រំសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ (កុមារអាយុពី១២-១៤ឆ្នាំ)

| សេវាអប់រំ | ភ្នាក់ងារផ្តល់សេវា | ពេលវេលា |
|---|---|---|
| – ៣កម្រិតថ្នាក់ (ថ្នាក់ទី៧ ដល់ថ្នាក់ទី៩) | – ក្រសួងឬមន្ទីរអប់រំ | |
| – កម្មវិធីសិក្សាប្រហែល១៩0ថ្ងៃក្នុង១ឆ្នាំ | | |
| – បណ្តុះបណ្តាល និងហ្វឹកហ្វឺនគ្រូបង្រៀន | – ក្រសួងឬមន្ទីរអប់រំ | – ២ឆ្នាំ |
| – ប្រាក់ឧបត្ថម្ភគ្រូបង្រៀនថែមម៉ោង | – ក្រសួងឬមន្ទីរអប់រំ | – ជាក់ស្តែង |
| – ការធ្វើផែនការអភិវឌ្ឍសាលារៀនប្រចាំឆ្នាំ | – សាលារៀន ឬ សហគមន៍ | – ខែសីហា ឬខែកញ្ញា |
| – សាលានីមួយៗទទួលបានថវិកា១,៥លានរៀល និង១៦.៥00រៀលក្នុងសិស្សម្នាក់ក្នុង១ឆ្នាំពីថវិកាសកម្មភាពជាអាទិភាពសម្រាប់ការអភិវឌ្ឍសាលារៀន : ជួសជុលសម្ភារ សាលាធុនតូច ផ្គត់ផ្គង់សម្ភារការិយាល័យ សម្ភារកីឡា ឧបករណ៍កសិកម្ម បរិស្ថាន ការហ្វឹកហ្វឺន គ្រូបង្រៀន | – ក្រសួងឬមន្ទីរអប់រំ | – ប្រចាំឆ្នាំសិក្សា |
| – ក្រសួង មន្ទីរ និងការិយាល័យអប់រំត្រួតពិនិត្យមើលពីការប្រើប្រាស់ថវិកាសម្រាប់សកម្មភាពអាទិភាពរបស់សាលា | – ក្រសួង មន្ទីរ និងការិយាល័យអប់រំ | – ទៀងទាត់ជាប្រចាំ |
| – ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ជាពិសេសសិស្សស្រី | – ក្រសួងឬមន្ទីរអប់រំ | |
| – ផ្តល់កន្លែងស្នាក់នៅដល់សិស្សក្រីក្រ | – ក្រសួងឬមន្ទីរអប់រំឬ សាលាឬអាជ្ញាធរមូលដ្ឋាន | |





# ៤. ការអប់រំអក្ខរកម្ម

ការលុបបំបាត់អនក្ខរភាព ជាគោលនយោបាយដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្របទៅតាមផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ដោយផ្តោតទៅលើការយកចិត្តទុកដាក់ចំពោះយុវជន (អាយុ១៥-២៤ឆ្នាំ) និងជនពេញវ័យ (អាយុ១៥-៤៥ឆ្នាំ) ជាពិសេសស្ត្រី កុមារី និងជនជាតិដើមភាគតិច។

## ៤.១. ស្ថានភាពអក្ខរកម្មនៅប្រទេសកម្ពុជា

នៅកម្ពុជាក្នុងចំណោមជនដែលមានអាយុ១៥ឆ្នាំឡើង គឺ ÷

- អត្រាអក្ខរជនមាន ៦៧,៣ភាគរយ
- អត្រាអនក្ខរជនមាន ៣២,៧ភាគរយ (ប្រមាណ១,៥លាននាក់ជាអនក្ខរជន)
- បុរសកម្ពុជា៨នាក់ក្នុងចំណោម១0នាក់ចេះអាន និងចេះសរសេរ
- ស្ត្រីកម្ពុជា៦នាក់ ក្នុងចំណោម១0នាក់ចេះអាន និងចេះសរសេរ។

## ៤.២. គោលបំណងនៃការអប់រំក្រៅប្រព័ន្ធ គឺដើម្បី :

- ជំរុញឱ្យកុមារអាយុពី៧-១២ឆ្នាំ ចូលរៀនក្នុងប្រព័ន្ធអប់រំមូលដ្ឋានវិញ (កម្មវិធីចូលរៀនឡើងវិញ)។
- ជំរុញឱ្យយុវជនជំទង់អាយុ១២-១៥ឆ្នាំ ទទួលបានវិញ្ញាបនបត្រសមមូលអប់រំជាមូលដ្ឋាន។

- ជំរុញយុវជននៅក្រៅសាលា ឱ្យទទួលបានកម្មវិធីអក្ខរកម្មពេញលេញ និងអភិវឌ្ឍន៍ការគ្រប់គ្រងជីវិត និងសមត្ថភាពបំពេញការងារ រួមទាំងបទពិសោធន៍ជាឪពុកម្តាយ និងជំនាញវិជ្ជាជីវៈងាយៗ ។
- ផ្តល់នូវអាកប្បកិរិយា ចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ការគ្រប់គ្រងជីវិត និងការងារ ។

## ៤.៣. សេចក្តីសន្និដ្ឋាន

យើងទាំងអស់គ្នា ត្រូវយល់ពីសារៈសំខាន់នៃការអប់រំសម្រាប់ទាំងអស់គ្នា ។ នោះវាមានន័យថា វាមិនមែនសម្រាប់តែកុមារអាយុ៦ឆ្នាំប៉ុណ្ណោះទេ គឺត្រូវគិតដល់កុមារដែលមានអាយុលើសពី៦ឆ្នាំ និងកុមារដែលបោះបង់ការសិក្សា ថាតើពួកគេទៅរៀនអាន និងសរសេរនៅឯណា? ត្រូវតែមានការខិតខំប្រឹងប្រែង ដើម្បីឱ្យកុមារបានចូលរៀននៅសាលាបឋមសិក្សាឡើងវិញ និងជំរុញយុវជននៅក្រៅសាលា ឱ្យទទួលបានកម្មវិធីអក្ខរកម្មពេញលេញ ។

ដើម្បីឱ្យសេវាកម្មនានាត្រូវបានផ្តល់យ៉ាងល្អ ភាគីពាក់ព័ន្ធត្រូវតែមានទំនាក់ទំនង សហការ និងបំពេញការងារឱ្យបានល្អ ដើម្បីឆ្ពោះទៅរកដំណោះស្រាយរួមមួយ ។ វាមានសារប្រយោជន៍ណាស់ ដែលឃុំ សង្កាត់ សហគមន៍ និងស្ថាប័នអប់រំផ្តល់ការគាំទ្រថ្នាក់អក្ខរកម្ម និងកម្មវិធីចូលរៀនឡើងវិញ ដើម្បីផ្តល់ឱកាសដល់កុមារ ដែលមិនធ្លាប់បានចូលសាលា និងកុមារដែលបោះបង់ការសិក្សា ឱ្យទទួលបាននូវអក្ខរកម្មពេញលេញ ។





# ៥. បំណិនជីវិត

## ៥.១. និយមន័យ

បំណិនជីវិត គឺជាសមត្ថភាពដែលមនុស្សគ្រប់រូបត្រូវមានជាចាំបាច់ ដើម្បីដោះស្រាយបញ្ហាជីវភាពរស់នៅជាក់ស្តែងប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ ។

**ឧទាហរណ៍ :**

- ប៉ិនប្រសប់ក្នុងការថែទាំកូនចៅ
- ប៉ិនប្រសប់ក្នុងការបើកបរប្រកបដោយសុវត្ថិភាព
- ប៉ិនប្រសប់ក្នុងការរៀបចំផែនការគ្រួសារ
- ប៉ិនប្រសប់ក្នុងការកាត់ដេរសម្លៀកបំពាក់
- ប៉ិនប្រសប់ក្នុងការសាងសង់ផ្ទះ
- ប៉ិនប្រសប់ក្នុងការទំនាក់ទំនង និងនិយាយស្តីជាមួយអ្នកភូមិ
- ប៉ិនប្រសប់ក្នុងការប្រមូលអ្នកភូមិឱ្យជួយគ្នាពេលមានបុណ្យទានផ្សេងៗ
- ប៉ិនប្រសប់ក្នុងការដាំដំណាំ ធ្វើស្រែចម្ការ
- ប៉ិនប្រសប់ក្នុងការដាំដើមឈើ

## ៥.២. ប្រភេទសំខាន់ៗនៃបំណិនជីវិត

បំណិនជីវិតមានច្រើនណាស់ តែបំណិនទាំងអស់នេះត្រូវបានបែងចែកជា៤ប្រភេទសំខាន់ៗ ៖

- បំណិនខាងសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន
- បំណិនក្នុងវិជ្ជាជីវៈបឋមដែលជួយឱ្យមានការងារធ្វើ
- បំណិនជីវិតក្នុងការរស់នៅក្នុងសង្គម សហគមន៍ (ប្រជាធិបតេយ្យ ច្បាប់ និងសិទ្ធិមនុស្ស)
- បំណិនក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការថែរក្សាបរិស្ថាន

**ឧទាហរណ៍បំណិនជីវិតតាមប្រភេទ**

| ប្រភេទនៃបំណិនជីវិត | ឧទាហរណ៍ |
|---|---|
| បំណិនខាងសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួន | ថែរក្សាសុខភាពខ្លួនបានល្អ ថែទាំកូនបានល្អ បើកបរបានល្អ គេចផុតពីការឆបោក . . . |
| បំណិនក្នុងវិជ្ជាជីវៈបឋមដែលជួយឱ្យមានការងារធ្វើ | ចេះកាត់ដេរបានល្អ ពូកែជួសជុលម៉ាស៊ីនបានល្អ ពូកែធ្វើជំនួញ ជាជាងឈើដ៏ពូកែ ពូកែសង់ផ្ទះ ពូកែធ្វើម្ហូប ពូកែធ្វើស្រែចម្ការ ពូកែចិញ្ចឹមសត្វ . . . |
| បំណិនជីវិតក្នុងការរស់នៅក្នុងសង្គម សហគមន៍ (ប្រជាធិបតេយ្យ ច្បាប់ និងសិទ្ធិមនុស្ស) | ពូកែទំនាក់ទំនង និយាយស្ដីជាមួយអ្នកភូមិ ពូកែប្រមូលប្រជាពលរដ្ឋឱ្យចេះជួយគ្នា សាមគ្គីគ្នា គោរពសិទ្ធិមនុស្ស គោរពច្បាប់ |





| ប្រភេទនៃបំណិនជីវិត | ឧទាហរណ៍ |
|---|---|
| | មានអធ្យាស្រ័យល្អ ពូកែវិភាគរកបញ្ហា និងដោះស្រាយបញ្ហា យល់ដឹងពីប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ក្នុងការរស់នៅ . . . |
| បំណិនក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការថែរក្សាបរិស្ថាន។ | ការពារព្រៃឈើបានល្អ ពូកែផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋការពារព្រៃឈើ សត្វព្រៃ យល់ដឹងពីការថែទាំអនាម័យ និងបរិស្ថាន ចេះធ្វើផែនការ ក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព . . . |

# ៦. សមភាពយេនឌ័រក្នុងការអប់រំ

## ៦.១. សេចក្តីផ្តើម

យើងបានដឹងថាមានឧបសគ្គមួយចំនួន ដែលធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធភាពរបស់កុមារីក្នុងការទទួលបាននូវផលប្រយោជន៍ ពីគោលនយោបាយនៃការអប់រំសម្រាប់ទាំងអស់គ្នា។ ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយអំពីសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី កុមារា និងកុមារី ក្នុងការទទួលសេវាសាធារណៈនានាយ៉ាងណាក៏ដោយ ក៏បច្ចុប្បន្ននេះ នៅតែមានគម្លាតរវាងកុមារា និងកុមារីក្នុងការទទួលបាននូវសេវាអប់រំ។ យោងតាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា (ស្ថិតិអាំងឌីកាទ័រអប់រំ ២០០៤-២០០៥) បានបង្ហាញឱ្យឃើញដូចខាងក្រោម ។

**អត្រានៃការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ២០០៤-២០០៥**

| កម្រិតសិក្សា | សិស្សស្រី | សិស្សប្រុស | សរុប | គម្លាតយេនឌ័រ |
|---|---|---|---|---|
| បឋមសិក្សា | ៩០,៧% | ៩៣,១% | ៩១,៩% | ២,៤% |
| មធ្យមសិក្សាបឋមភូមិ | ២៤,៨% | ២៧,៣% | ២៦,១% | ២,៥% |

ទិន្នន័យខាងលើមានន័យថា ក្នុងចំនួនកុមារី១០០នាក់ ដែលមានវ័យត្រូវរៀននៅបឋមសិក្សា មានតែកុមារីចំនួនប្រមាណ៩១នាក់ទេ ដែលបានចូលរៀនពិតប្រាកដ។ ក្នុងចំនួនកុមារា១០០នាក់ ដែលមានវ័យត្រូវរៀននៅបឋមសិក្សា មានចំនួនប្រមាណ៩៣នាក់ បានចូលរៀនពិតប្រាកដ។ មានន័យថា គម្លាតយេនឌ័រនៅក្នុងការសិក្សានៅបឋមសិក្សា គឺមាន **២,៤ ភាគរយ** សរុបទូទាំងប្រទេស។





ដោយឡែក ខេត្តមួយចំនួនមានគម្លាតយេនឌ័រច្រើនជាងនេះ ជាក់ស្តែងខេត្តរតនគិរី គឺមានគម្លាតយេនឌ័រ រហូតដល់**១៧ភាគរយ**។

នៅមធ្យមសិក្សាបឋមភូមិ ក្នុងចំនួនកុមារី១០០នាក់ មានតែកុមារីចំនួនប្រមាណតែ២៥នាក់ទេ ដែលបានចូលរៀនពិតប្រាកដ។ ក្នុងចំនួនកុមារា ១០០នាក់ មានចំនួនប្រមាណ២៧នាក់ ដែលបានចូលរៀនពិតប្រាកដ។ ដូចនេះ គម្លាតយេនឌ័រនៅក្នុងការសិក្សានៅមធ្យមសិក្សាបឋមភូមិ គឺមាន **២,៥ភាគរយ** សរុបទូទាំងប្រទេស។

យោងតាមទិន្នន័យខាងក្រោមនេះ យើងពិនិត្យឃើញថាទាំងនៅបឋមសិក្សា ក៏ដូចជាមធ្យមសិក្សាបឋមភូមិដែរ មានចំនួនកុមារីជាច្រើនបានបោះបង់ចោលការសិក្សា។ ជាក់ស្តែង អត្រាបញ្ចប់ការសិក្សានៅថ្នាក់ទី៦របស់កុមារីមានតែ **៤៥,៧១ភាគរយ** និងអត្រាបញ្ចប់ការសិក្សានៅថ្នាក់ទី៩ របស់កុមារីមានតែ **១៩,៩៧ភាគរយ**។

## ៦.២. និយមន័យសមភាពយេនឌ័រ

សមភាពយេនឌ័រមានន័យថា នារី បុរស កុមារី និងកុមារា មានសិទ្ធិក្នុងការទទួលផលប្រយោជន៍ ក៏ដូចជាការទទួលខុសត្រូវក្នុងសង្គម ការទទួលស្គាល់ស្មើភាពគ្នានៅចំពោះមុខច្បាប់ សមភាពចំពោះសេវាសង្គម ដូចជាការអប់រំ និងការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមានតម្លៃប្រហាក់ប្រហែលគ្នា។

## ៦.៣. ទស្សនៈយល់ដឹងស្តីពីផលប៉ះពាល់លើការអប់រំកុមារី

- **ទស្សនៈទី១ :** អប់រំកុមារីម្នាក់ គឺអប់រំគ្រួសារទាំងមូល
- **ទស្សនៈទី២ :** នៅពេលដែលចំនួនកុមារីក្លាយជាអក្ខរជន (អ្នកចេះអក្សរ) កើនឡើង អត្រាមរណភាពរបស់កុមារអាយុក្រោម១ឆ្នាំធ្លាក់ចុះយ៉ាងឆាប់រហ័ស ។

**ការស្រាយបំភ្លឺទស្សនៈខាងលើ កុមារីដែលទទួលបានការអប់រំល្អ នាងនឹងក្លាយជាអ្នក ÷**

- មានសមត្ថភាព ក្នុងការអប់រំគ្រួសាររបស់នាង ។
- មានសមត្ថភាព និងលទ្ធភាពខ្ពស់ទាំងនៅផ្ទះ និងនៅក្នុងក្របខ័ណ្ឌការងារ ហើយជាពិសេសក្នុងការបំពេញការងារដែលទទួលបានប្រាក់ចំណូលច្រើនសម្រាប់ផ្គត់ផ្គង់គ្រួសារ ។
- យល់ដឹងច្បាស់ពីសារៈសំខាន់នៃការអប់រំ ហើយនឹងបញ្ជូនកូនៗរបស់នាង ទៅសាលារៀនដែលធ្វើឱ្យគ្រួសារនាងមានអនាគតល្អ ។
- មានការយល់ដឹងច្បាស់ អំពីរបៀបនៃការថែទាំសុខភាព និងយកចិត្តទុកដាក់ថែទាំកូនៗរបស់នាងបានល្អប្រសើរ ។
- មានសមត្ថភាពក្នុងការគ្រប់គ្រងធនធានក្នុងគ្រួសារបានល្អប្រសើរ ។
- មានជំនាញច្បាស់លាស់ និងមានទំនុកចិត្តលើខ្លួនឯង ដើម្បីធ្វើខ្លួនជាម្តាយ អ្នកដឹកនាំ មន្ត្រី និងជាប្រជាពលរដ្ឋល្អនៅក្នុងសង្គម ។





# ៧. គុណភាពនៃការអប់រំ

## ៧.១. កត្តាសំខាន់ៗពាក់ព័ន្ធនឹងគុណភាពនៃការអប់រំ

ដើម្បីឱ្យការអប់រំមានគុណភាពល្អប្រសើរ លុះត្រាតែ :

- **សិស្ស :** កុមារមានសុខភាពល្អ ឧស្សាហ៍ព្យាយាម មករៀនទៀងទាត់ សីលធម៌រស់នៅល្អ សហការរៀនសូត្រ ជួយមិត្តភក្តិ លទ្ធផលសិក្សាបានល្អប្រសើរ . . .។ល។
- **គ្រូបង្រៀន :** បែងចែកគ្រូបង្រៀនតាមនិយាម មានការបំប៉នសមត្ថភាពគ្រូបង្រៀនជាប្រចាំ អធិការកិច្ចគ្រូ គាំទ្រ និងលើកទឹកចិត្តគ្រូ គ្រូមានគុណភាព ហើយបង្រៀនតាមកម្មវិធីត្រឹមត្រូវ និងមានសម្ភារបង្រៀនគ្រប់គ្រាន់ ព្រមទាំងគ្រូមានមនសិការវិជ្ជាជីវៈខ្ពស់ . . .។ល។
- **ការគ្រប់គ្រងសាលារៀន :** មានរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ (គណៈគ្រប់គ្រងសាលារៀន គណៈកម្មការកម្រងសាលា គណៈកម្មការទ្រទ្រង់សាលា...) ដោយមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ មានទំនាក់ទំនងល្អ ជំរុញការអនុវត្តផែនការរបស់គណៈកម្មការ មានការប្រជុំទៀងទាត់ និងមានប្រព័ន្ធពិនិត្យតាមដានច្បាស់លាស់ . . .។ល។

- **បរិស្ថានសាលារៀន** ៖ មានអគារសិក្សា និងថ្នាក់រៀនស្អាត សោភ័ណភាពល្អត្រកាល មានទីធ្លាសម្រាប់សិស្សលេងសមរម្យ មានរបង ដងទង់ជាតិ រុក្ខជាតិ សួនផ្កា សួនច្បារ បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាត ទីធ្លាកីឡាគ្រប់គ្រាន់ និងមានសុវត្ថិភាពល្អ . . . ។ល។
- **អាជ្ញាធរមូលដ្ឋាន** ៖ មានការគាំទ្រ និងចូលរួមសកម្មភាពអភិវឌ្ឍន៍សាលារៀន ចូលរួមក្នុងការកសាងផែនការ និងគ្រប់គ្រងថវិកា តាមដានការប្រើប្រាស់ថវិកា និងចូលរួមវាយតម្លៃគុណភាពអប់រំជាប្រចាំ។
- **សហគមន៍ និងមាតាបិតាសិស្ស** ៖ មាតាបិតាជំរុញកុមារឱ្យមកសាលារៀន គាំទ្រ និងចូលរួមសកម្មភាពអភិវឌ្ឍន៍សាលារៀន ចូលរួមក្នុងការកសាងផែនការ និងតាមដានការប្រើប្រាស់ថវិកា និងចូលរួមវាយតម្លៃគុណភាពអប់រំជាប្រចាំ។

## ៧.២. អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការចូលរួមកែលម្អគុណភាពអប់រំ

- ស្ថាប័នអប់រំ និងសាលារៀន
- អាជ្ញាធរមូលដ្ឋាន ( ក្រុមប្រឹក្សាឃុំ សង្កាត់)
- សហគមន៍ ឬអាណាព្យាបាលសិស្ស





### តួនាទីចូលរួមកែលម្អគុណភាពអប់រំរបស់អ្នកពាក់ព័ន្ធ

| សមាស | តួនាទីរបស់អ្នកពាក់ព័ន្ធ | | |
|---|---|---|---|
| ភាគ | ស្ថាប័នអប់រំ និងសាលារៀន | ក្រុមប្រឹក្សាឃុំ សង្កាត់ | សហគមន៍ អាណាព្យាបាល |
| សិស្ស | – ផ្តល់សៀវភៅអានដល់សិស្សឱ្យបានគ្រប់គ្នា និងឥតគិតថ្លៃ<br>– ធានាឱ្យមានបន្ទប់រៀនគ្រប់គ្រាន់សម្រាប់សិស្ស | – ប្រមូលព័ត៌មានស្ថិតិកុមារដល់វ័យសិក្សា និងកុមារបោះបង់ការសិក្សា<br>– ចុះបញ្ជីកំណើត<br>– ការពារសុខសុវត្ថិភាពដល់កុមារនៅពេលទៅសាលា និងពេលត្រឡប់មកផ្ទះ | – បញ្ជូនកុមារឱ្យចូលរៀនពេលកុមារដល់វ័យសិក្សា<br>– លើកទឹកចិត្តកុមារឱ្យខិតខំរៀន<br>– ថែទាំកុមារឱ្យមានសុខភាពល្អ<br>– ផ្តល់ឱកាសដល់កុមារក្នុងការសិក្សាឱ្យបានគ្រប់គ្រាន់ |
| គ្រូបង្រៀន | – ធានាបែងចែកគ្រូបង្រៀនតាមនិយាម<br>– ធានាការបំប៉នសមត្ថភាពគ្រូ<br>– អធិការកិច្ចគ្រូ<br>– គាំទ្រ និងលើកទឹកចិត្តគ្រូ | – ជួយពិនិត្យវត្តមាន និងរាយការណ៍ទៅគណៈគ្រប់គ្រងសាលារៀន<br>– ផ្តល់កន្លែងស្នាក់នៅដល់គ្រូបង្រៀនមកពីតំបន់ឆ្ងាយ<br>– ការពារសុខសុវត្ថិភាពជូនគ្រូ | – ផ្តល់ព័ត៌មានត្រឡប់ពីវត្តមានរបស់សិស្ស<br>– ចូលរួមលើកទឹកចិត្តដល់គ្រូបង្រៀនដែលមានស្នាដៃល្អ<br>– ឧបត្ថម្ភគ្រូមកពីតំបន់ឆ្ងាយ<br>– ជួយការពារសុខសុវត្ថិភាពគ្រូ |

| សមាសភាគ | តួនាទីរបស់អ្នកពាក់ព័ន្ធ | | |
|---|---|---|---|
| | ស្ថាប័នអប់រំ និងសាលារៀន | ក្រុមប្រឹក្សាឃុំ សង្កាត់ | សហគមន៍ អាណាព្យាបាល |
| ការគ្រប់គ្រងសាលារៀន | – ជំរុញការអនុវត្តផែនការអភិវឌ្ឍន៏សាលារៀន<br>– កសាងសមត្ថភាពគ្រប់គ្រងដល់នាយកសាលា | – ផ្តល់យោបល់លើការអភិវឌ្ឍសាលា និងគុណភាពអប់រំ<br>– ផ្តល់ព័តិមានស្ថិតិរបស់កុមារអវត្តមានឬបោះបង់ការសិក្សាបានទាន់ពេលវេលា<br>– ផ្តល់ទីតាំងសាងសង់សាលា | – សហការល្អក្នុងការអភិវឌ្ឍសាលារៀន<br>– គាំទ្រការអនុវត្តផែនការកែលម្អគុណភាពអប់រំ<br>– ចូលរួមប្រជុំដោះស្រាយបញ្ហា ផ្តល់យោបល់កែលម្អ |
| បរិស្ថានសាលារៀន | – ស្វែងរកការគាំទ្រលើការអភិវឌ្ឍបរិស្ថានសាលា<br>– ផ្សព្វផ្សាយព័តិមានអប់រំអនាម័យសាលារៀន<br>– រៀបចំកែលម្អសោភ័ណភាពសាលារៀន | – ធានាឱ្យមានបង្គន់អនាម័យ អណ្តូងទឹកសួនច្បារនៅក្នុងទីធ្លាសាលា . . .<br>– ជួសជុលអគារសិក្សាសម្ភារប្រើប្រាស់របស់សាលា<br>– ធានាសុខសុវត្ថិភាពបរិស្ថានសាលារៀន | – គាំទ្រសកម្មភាពថែរក្សាអនាម័យសាលារៀន<br>– រួមចំណែកការពារនិងកែលម្អបរិស្ថានសាលារៀន<br>– ចូលរួមសាងសង់អគារសិក្សា របងសាលារៀន បង្គន់អនាម័យ ផ្តល់កូនឈើ . . . |





| សមាសភាគ | តួនាទីរបស់អ្នកពាក់ព័ន្ធ | | |
|---|---|---|---|
| | ស្ថាប័នអប់រំ និងសាលារៀន | ក្រុមប្រឹក្សាឃុំ សង្កាត់ | សហគមន៍ អាណាព្យាបាល |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | – សហការឱ្យបានជិតស្និទ្ធក្នុងការដោះស្រាយបញ្ហាផ្សេងៗ (រក្សាសណ្តាប់ធ្នាប់សន្តិសុខ)<br>– សហការក្នុងការប្រមូលទិន្នន័យកុមារដែលត្រូវចូលរៀន និងបោះបង់ចោលការសិក្សា | – បញ្ចូលសកម្មភាពកែលម្អគុណភាពអប់រំទៅក្នុងសកម្មភាពជាអាទិភាពរបស់ឃុំ សង្កាត់<br>– ផ្សព្វផ្សាយព័តិមានអប់រំ<br>– ដាក់បញ្ហាអប់រំទៅក្នុងរបៀបវារៈប្រជុំជាប្រចាំ<br>– រៀបចំឱ្យអ្នកមានសមត្ថភាពទទួលបន្ទុកការងារអប់រំ | – ផ្តល់ព័តិមានស្តីពីស្ថិតិកុមារ<br>– ជំរុញឱ្យដាក់សកម្មភាពអាទិភាពអប់រំទៅក្នុងផែនការអភិវឌ្ឍន៏ឃុំ សង្កាត់<br>– ផ្តល់ព័តិមានស្តីពីសុខសុវត្ថិភាពមូលដ្ឋានដល់អាជ្ញាធរ<br>– ចូលរួមអនុវត្តសកម្មភាពកែលម្អគុណភាពអប់រំ |
| សហគមន៍ និងមាតាបិតាសិស្ស | – សហការឱ្យបានជិតស្និទ្ធ ផ្សព្វផ្សាយព័តិមានអប់រំឱ្យបានទាន់ពេលវេលា<br>– ជំរុញសហគមន៏ឱ្យចូលរួមក្នុងការអភិវឌ្ឍសាលារៀន | – ចូលរួមគាំទ្រជំរុញសហគមន៏ក្នុងការអភិវឌ្ឍសាលារៀន<br>– ជំរុញមាតាបិតាសិស្សឱ្យបញ្ជូនកូនទៅរៀន<br>– កៀរគរធនធានដើម្បីអភិវឌ្ឍន៏សាលារៀន<br>– ផ្សព្វផ្សាយសារៈសំខាន់នៃការអប់រំសម្រាប់កុមារពិសេសកុមារី | – ចូលរួមការប្រជុំយ៉ាងសកម្មនិងផ្តល់ព័តិមានត្រឡប់ទាក់ទងដល់ការចូលរួមវិភាគទាន<br>– កៀរគរធនធានដើម្បីគាំទ្រការអភិវឌ្ឍសាលា<br>– ផ្សព្វផ្សាយពីសារៈសំខាន់នៃការបញ្ជូនកូនទៅរៀន |

## ៧.៣. សេចក្តីសន្និដ្ឋាន

បើចង់ឱ្យកុមារ និងស្ត្រីនៅក្នុងសហគមន៍មានឱកាសគ្រប់គ្រាន់ និងមានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការទទួលបានការអប់រំ យើងទាំងអស់គ្នាត្រូវតែខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅទាំង៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា។ បើចង់កាត់បន្ថយភាពក្រីក្រក្នុងសង្គមជាតិយើង យើងទាំងអស់គ្នា ត្រូវតែធានាឱ្យបានការអប់រំប្រកបដោយគុណភាព។ ដូច្នេះគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវតែអនុវត្តតាមតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់តាមគោលការណ៍អប់រំ **"ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាសម្រាប់ការអប់រំ"**។